**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ

# សារាចរណែនាំ
## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា
## ខេត្ត ក្រុងឆ្នាំ ២០០៦

យោងសារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦

យោងប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកាខេត្ត ក្រុង ឆ្នាំ ២០០៦ ដូចតទៅ ÷

## I. ការរៀបចំចំណូលថវិកា :

1. ការគិតគូរចំណូលចរន្តរបស់ថវិកាខេត្ត ក្រុង អាស្រ័យទៅលើប្រភពនៃផលិតផល ឬ ផលទុន ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ។

ផ្អែកតាមប្រភពធនធានខាងលើនេះ អភិបាលខេត្ត ក្រុងត្រូវរៀបចំទូវគំរោងចំណូលថវិការបស់ខេត្ត ក្រុងសាមីដូចតទៅ ÷

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  + លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  + ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  + ប៉ាន់ស្មានលើការវិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើង ឬត្រូវពិនិត្យពិចារណាលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
  + ចំណូលដែលសង្ឃឹមថាបានមកពីការបង្កើតពន្ធថ្មី (ករណីមានគោលនយោបាយថ្មី) ។

- ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានផលទុន ដូចជាកិច្ចសន្យាជួល សេវាកម្ម។ល។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសំរេចបាននៃឆ្នាំកន្លងមក និង ការវិវឌ្ឍន៍នៃសេដ្ឋកិច្ច ។

ចំពោះនីតិវិធី គឺអភិបាលខេត្ត ក្រុង ត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាខាពន្ធដារ និងមន្ទីរជំនាញដែលពាក់ព័ន្ធ ក្នុងការប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ សំរាប់ថវិកាខេត្ត ក្រុង ដើម្បីមកចូលរួមពិភាក្សាគិតគូររៀបចំជាគំរោងចំណូលសរុប ទៅតាមតារាងឧបសម្ព័ន្ធទី១ ដែលជូនភ្ជាប់មកជាមួយនេះ ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិកាខេត្ត ក្រុង ក្នុងករណីដែលមាន គឺត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុងគំរោងចំណូល ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេសដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង រួចហើយនោះ ។

## II. ការរៀបចំចំណាយថវិកា

3. ខេត្ត ក្រុងត្រូវរៀបចំនូវគំរោងចំណាយសំរាប់រាល់សកម្មភាពសេវាទាំងអស់ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ ដែលស្ថិតនៅក្រោមនិវាទរបស់ខ្លួន ។ របៀបគិតគូរនូវតំរូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗដោយច្បាស់លាស់ និងដោយផ្អែកទៅ លើកត្តានានា ដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះ ដូចជា តារាងបុគ្គលិក បញ្ជីទ៉ាន់ស្មានបរិមាណ តំលៃ សម្ភារៈ ឬសេវា... ។ ចំពោះសកម្មភាពមួយចំនួនទាមទារអោយមានបង្កើតធម្មនិយាមសមស្រប ដូចជា ចំណាយជួសជុលក្នុងមួយម៉ែត្រការ៉េ ចំនួនទឹកប្រាក់ចាំបាច់ សំរាប់ផ្ទៃក្រឡាណាមួយ ការប្រើប្រាស់គ្រឿងចក្រគិតជា ប្រេងឥន្ធនៈ ការសិកវិចនៃសំបកកង់រថយន្តគិតជាគីឡូម៉ែត្រជាដើម ។ ចំពោះសម្ភារៈបរិក្ខារដែលប្រើប្រាស់ជាប្រចាំ ត្រូវគិតគូរដោយផ្អែកតាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគនៃបណ្ដាឆ្នាំកន្លងមក ។ ចំណែកឯ សោហុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្ដីពីការកំណត់ប្រាក់របបបេសកកម្មក្នុងនិងក្រៅប្រទេស) និងប្រាក់ឈ្នួលផ្ទះ ទឹកភ្លើងរបស់អភិបាល អភិបាលរងគ្រប់ខេត្ត ក្រុងត្រូវអនុវត្តផ្អែកលើមូលដ្ឋានអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការទីប្រឹក្សាព្រមទាំងមន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ ។

គំរោងចំណាយទាំងអស់របស់ថវិកាខេត្ត ក្រុង ត្រូវបានសរុបនៅក្នុងតារាងឧបសម្ព័ន្ធទី២ ដែលជូនភ្ជាប់មកជាមួយនេះ ។

4. ជាទូទៅ សំណើចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយ តាមជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ដើម្បីបង្ហាញអោយឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវ ហ្មត់ចត់ និងសមហេតុផល ។ លិខិតយុត្តិការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

5. សារាចរណែនាំនេះ ក៏មានភ្ជាប់ជាមួយនូវសលាកប័ត្រគំរូមួយចំនួនសំរាប់បំពេញនូវឥណទាន ដែលត្រូវស្នើសុំទៅតាមមុខចំណាយនីមួយៗ ។ សលាកប័ត្រទាំងអស់នេះ ត្រូវបានអង្គភាពនានារបស់ខេត្ត ក្រុង ប្រើប្រាស់ សំរាប់ផ្ដល់នូវពត៌មានបន្ថែម ទៅលើការស្នើសុំឥណទានរបស់ខ្លួន ។

### II.1 ការរៀបចំគំរោងចំណាយចរន្ត

6. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ÷

### ប្រភេទ ១ : មធ្យោបាយសេវា

### ជំពូក១០ : ប្រាក់បៀវត្ស និង ប្រាក់បំណាច់

7. ចំណាយសំរាប់បុគ្គលិកត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ចំណាយលើជំពូកនេះ ត្រូវបានចាត់ទុកជា

ចេញដោយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ មន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៥ មន្ត្រីរាជការដែលចូលនិវត្តន៍ ត្រូវផ្ទេរចេញពីក្របខ័ណ្ឌ និងមន្ត្រីមរណៈដែលត្រូវកាត់បន្ថយពីអង្គភាពរបស់ខ្លួន នៅឆ្នាំ ២០០៦ ខាងមុខនេះរាជរដ្ឋាភិបាលនឹងបង្កើនប្រាក់បៀវត្សមូលដ្ឋានចំនួន ១៥ភាគរយ ដែលនឹងប្រើឥណទាននៃមូលនិធិបម្រុង។ ចំពោះគំរោង ចំណាយអំពីប្រាក់បំណាច់បុគ្គលិកអណ្តែត និងគំរោងចំណាយអំពីលាភការភ្នាក់ ងារជាប់កិច្ចសន្យា គឺចាំបាច់ត្រូវតែមានសេចក្តីសំរេចអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្របខ័ណ្ឌឥណទានដែលបានពិភាក្សា រួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ក. បុគ្គលិកដែលកំពុងមានក្នុងពេលបច្ចុប្បន្ន

8. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទខេត្ត ក្រុង ត្រូវបូកសរុបនៅក្នុងសលាកប័ត្រ១ ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលខេត្ត ក្រុងមាន ។

9. សលាកប័ត្រ១នេះ គឺសំរាប់សរុបបុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាង ប្រព័ន្ធប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ) ។

10. ខេត្ត ក្រុងត្រូវលំអិតចំនួនបុគ្គលិកទៅតាមស្រុក ខ័ណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

## ខ. ការជ្រើសរើសបុគ្គលិកថ្មី

11. អភិបាលខេត្ត ក្រុង តែងតាំងបុគ្គលិកខេត្ត ក្រុងក្នុងក្របខ័ណ្ឌនៃថវិការបស់ខេត្ត ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋានដោយឡែកដែលមានជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤, ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមកាតព្វកិច្ចរបស់ភ្នាក់ងារសាធារណៈទាំងអស់ ។ ខេត្ត ក្រុងអាចសំរេចជ្រើសរើសអោយចូលធ្វើការចំពោះបុគ្គលិកប្រភេទ "គ" និង"ឃ" ក្នុងករណីដែលចាំបាច់បំផុតបន្ទាប់ពីបានប្រើប្រាស់អោយអស់លទ្ធភាពនូវមន្ត្រីរាជការដែលមានស្រាប់ ប្រការនេះគឺជាគោលការណ៍រួមតែប៉ុណ្ណោះ។ បច្ចុប្បន្នក្នុងពេលដែលរាជរដ្ឋាភិបាលកំពុងដំណើរការ កែទំរង់រដ្ឋបាលសាធារណៈនិងធ្វើវិចារណកម្មលើចំនួនក្របខ័ណ្ឌមន្ត្រីរាជការនោះ ខេត្ត ក្រុងមិនត្រូវបានអនុញ្ញាតអោយជ្រើសរើសបុគ្គលិកថ្មីទេ ។

## ជំពូក១១ : ដំណើរការរដ្ឋបាល សម្ភារៈនិងការជួសជុលតូច

12. ជំពូក១១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបានហ្មត់ចត់ និងសន្សំសំចៃបំផុត ក្នុងឆ្នាំ២០០៦ ផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈចំណាយឥណទានផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិត៩៣ភាគរយនៃឆ្នាំ ២០០៥ តែប៉ុណ្ណោះ ។ ដោយឡែកការកាត់បន្ថយចំនួន ៧ភាគរយនេះ គឺបង្ហាញអោយឃើញអំពីភាពហ្មឺងម៉ាត់របស់រាជរដ្ឋាភិបាលក្នុងការសន្សំសំចៃថវិកាទុកសំរាប់ដោះរំលស់បំណុលសាច់ប្រាក់កក្ស្ទះនៅធនាគារជាតិ និងសំរាប់បង្កើនចំណាយវិនិយោគសាធារណៈនិងចំណាយលើការថែទាំនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសផ្លូវស្ពាន និងប្រព័ន្ធស្រោចស្រព។

មួយផ្នែកទៀតជា ឥណទានសំរាប់បំរើផលប្រយោជន៍របស់ខេត្ត ក្រុង ( ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤ ) ក្នុងការរៀបចំមូលដ្ឋានសំភារៈនៃសេវាសាធារណៈ និងការអភិវឌ្ឍន៍របស់ខេត្ត ក្រុង ។ ផ្អែកលើផែនការអភិវឌ្ឍន៍ខេត្ត ក្រុងរបស់ក្រសួងមហាផ្ទៃ ខេត្ត ក្រុងនីមួយៗ ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយអាទិភាពនៃគំរោងចំណាយលំអិតអំពីការងារជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សានៃគំរោងថវិកាប្រចាំឆ្នាំ ។សលាកបត្រយុត្តិការដែលមានខាងក្រោមនេះ សំរាប់បង្ហាញនូវខ្ទង់ចំណាយសំខាន់ៗ ក្នុងជំពូក១១ របស់អង្គភាពនីមួយៗដែលមានការពាក់ព័ន្ធ ។

- អសង្ហារិម (សលាកបត្រ២) : ឥណទានត្រូវបានបែងចែកតាមកន្លែងដែលប្រើប្រាស់គ្រឿងអសង្ហារិម ដូចជា កន្លែងរដ្ឋបាល ឬនិវាសនដ្ឋាន និងតាមប្រភេទចំណាយ ដូចជាការថែទាំ ការប្រើប្រាស់ទឹក អគ្គិសនីជាដើម ។
- ចលនវត្ថុ សម្ភារៈ (សលាកបត្រ៣) : គប្បីបែងចែកដាច់ពីគ្នារវាងការទិញនិងការថែទាំ ។ ចំពោះសម្ភារៈការិយាល័យមានខ្ទង់មួយសំរាប់បំពេញក្នុងសលាកបត្រនេះ ។
- រថយន្ត (សលាកបត្រ៤) : ជាទូទៅ ចំណាយលើការប្រើប្រាស់និងថែទាំរថយន្ត មានទំហំធំធេងណាស់ បើប្រៀបធៀបនិងប្រភេទចំណាយឯទៀត ។ ដូច្នេះអង្គភាពនីមួយៗត្រូវខិតខំយ៉ាងណា ដើម្បីខ្ទប់ចំណាយនេះកុំអោយលើសពីកំរិតដែលសមស្រប ។ ការធ្វើយុត្តិកម្មឥណទាន ត្រូវតែមានភាពច្បាស់លាស់ និងត្រូវផ្អែកទៅលើគុណភាពរថយន្ត ម៉ាករថយន្ត ផ្លាកលេខ ឆ្នាំទិញ ចម្ងាយផ្លូវដែលបានបើកបរគិតជាគីឡូម៉ែត្រ រីឯការគ្រោងឥណទានអនុញ្ញាតអោយគ្រោង បានចំពោះតែរថយន្តស្ថិតក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋតែប៉ុណ្ណោះ ។ ដោយហេតុនេះហើយ ត្រូវបែងចែកឥណទានដែលស្នើសុំ ទៅតាមឥណទានសំរាប់ការថែទាំ សំរាប់ប្រេងឥន្ធនៈ និងសំរាប់ប្រេងរំអិល ។
- សោហ៊ុយធ្វើដំណើរ (សលាកបត្រ៥) : គឺជាប្រាក់សំរាប់ធ្វើដំណើរ របស់មន្ត្រីរាជការចេញទៅបំពេញបេសកកម្ម ។ ប្រការនេះ គឺត្រូវបែងចែកអោយដាច់ពីគ្នាទៅតាមប្រភេទបេសកកម្ម ដូចដែលបានចែងក្នុងអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ មេសា ឆ្នាំ ២០០៤ ។
- ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ដូចជាចំណាយបំភ្លឺសាធារណៈ ការប្រមូលសំរាម ថែទាំផ្លូវថ្នល់ សួនច្បារសាធារណៈ ប្រឡាយ លូទឹកជាដើម ត្រូវមានគំរោងលំអិតសំរាប់មុខសញ្ញានីមួយៗ និងត្រូវបញ្ជាក់នូវទីតាំង ភូមិ ឃុំ សង្កាត់ និងស្រុក ខ័ណ្ឌអោយបានច្បាស់លាស់ ។
- ចំណាយទទួលភ្ញៀវ ទស្សនៈកិច្ចនិងប្រជុំ ត្រូវគ្រោងអោយស្ថិតនៅក្នុងកំរិតមួយសមស្របដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់និងមិនធ្វើអោយបាត់តុល្យភាពថវិកា ។ ចំពោះខេត្ត ក្រុង ដែលទទួលការឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ ត្រូវគ្រោងចំណាយប្រភេទនេះក្នុងកំរិតទាបបំផុត ។

13. សលាកបត្រទាំងប៉ុន្មាននេះ មិនអាចប្រើប្រាស់ជាលិខិតយុត្តិការចាំបាច់បានគ្រប់គ្រាន់ទេ ដោយគ្រាន់តែធ្វើជាមូលដ្ឋានសំរាប់រៀបចំគំរោងថវិកាអោយស្ថិតក្នុងកំរិតមួយសមស្រប នៅក្នុងការគិតគូរនិងឆ្លើយតបទៅនិងគោលដៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈតែប៉ុណ្ណោះ ។ សលាកបត្រមានច្រើនប្រភេទបែបនេះ គឺសំរាប់ធានាអោយបាននូវសុពលភាពនៃគំរោងចំណាយ និងភ្ជាប់ជាមួយនូវសំណុំឯកសារ ដើម្បីបង្ហាញនូវថវិកាជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

14. ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប ។ ម្យ៉ាងទៀត ខេត្ត ក្រុងមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងយ៉ាងម៉ឹងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសំរាប់ចំណាយទូរស័ព្ទ អគ្គីសនី ទឹក ខេត្ត ក្រុងត្រូវគ្រោងអោយបានគ្រប់គ្រាន់សំរាប់តំរូវក្នុងឆ្នាំ និងការសងបំណុល ក្នុងករណីដែលខេត្ត ក្រុងគ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងថវិការបស់ខេត្ត ក្រុង និងដាក់កម្មវិធីចំណាយសំរាប់ទូទាត់ជូនខេត្ត ក្រុងដោយស្វ័យប្រវត្តិ ។

15. ចំពោះឥណទានសំរាប់ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង (ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ខេត្ត ក្រុងត្រូវគ្រោងឥណទានដោយលំអិតតាមវាក្យខ័ណ្ឌនីមួយៗ ហើយក្នុងវាក្យខណ្ឌនីមួយៗ ក៏ត្រូវមានគំរោងលំអិតតាមការដ្ឋាននីមួយៗដោយមានបញ្ជាក់អំពីបញ្ជីចំណាត់តម្លៃ និងទីតាំងច្បាស់លាស់សំរាប់យកមកពិភាក្សាសំរេចជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពេលតែមួយនៃការពិភាក្សាថវិកាប្រចាំឆ្នាំ ។

**ជំពូក១២ : ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល**

16. ចំណាយក្នុងជំពូកនេះសំរាប់ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល ដែលខេត្ត ក្រុងបង្កើតឡើងហើយកំពុងសេវាសាធារណៈ ដែលទទួលបានពុំអាចរ៉ាប់រងបាននូវរាល់ការចំណាយចាំបាច់ ។

## ប្រភេទ ៣ : ចំណាយអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

17. ចំពោះចំណាយប្រភេទនេះ ត្រូវចែងលំអិតអោយបានច្បាស់លាស់ នូវគោលដៅដែលត្រូវសំរេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះអោយបានហ្មត់ចត់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន ។

## ប្រភេទ ៤ : ចំណាយផ្សេងៗ និងចំណាយមិនបានគ្រោងទុក

18. ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសំរាប់ចំណាយផ្សេងៗ ដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត ។ សំរាប់ឆ្នាំថវិកា២០០៦ប្រភេទឥណទាន គឺអនុញ្ញាតអោយគ្រោងចំនួន ៣ ភាគរយ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញអោយជំពូកដទៃទៀត ដែលជាតំរូវការចំណាយផ្សេងៗកើតមានឡើងដោយយថាហេតុ ។

19. ចំណាយជាមូលធន គឺជាចំណាយសំរាប់ធ្វើហិរញ្ញប្បទានចំពោះគំរោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុននិងសំដៅធ្វើអោយសំរេចតាមគោលដៅដែលបានដាក់ចេញ ។

20. គំរោងវិនិយោគរបស់ខេត្ត ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងបានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការ អោយគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិកាខេត្ត ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងមានចំណូលជាមូលធនផ្ទៃក្នុងខេត្ត ក្រុងផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬ គំរោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលឬម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង ដើម្បីកត់ត្រាចូលទៅក្នុងគំរោងថវិការបស់ខេត្ត ក្រុង ។ ទន្ទឹមនឹងនេះក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគំរោង ដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

## III. គំរោងចំណូល ចំណាយសរុប

**21.** គំរោងចំណូល ចំណាយថវិការបស់ខេត្ត ក្រុងនីមួយៗដែលបានគិតគូរ រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗផង ។ គំរោងចំណូលចំណាយនេះ ត្រូវរៀបចំអោយមានគុណភាពពិតប្រាកដ ហើយត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកាមួយ ដែលមានប្រភពធនធានរួមផ្សំឡើងដោយការឧបត្ថម្ភមានកំរិតកំណត់ពីថវិការដ្ឋ និងលទ្ធភាពពិតប្រាកដនៃការប្រមូលចំណូលផ្ទាល់របស់ខេត្ត ក្រុង ។

**22.** ចំពោះខេត្តបាត់ដំបង និងខេត្តសៀមរាប គំរោងចំណាយត្រូវភ្ជាប់មកជាមួយនូវគំរោងចំណាយរបស់ស្រុកដំបងបាត់ និងស្រុកសៀមរាប ដែលខេត្តត្រូវបែងចែក (តាមរូមមន្តបែងចែកចំណាយឆ្នាំ ២០០៥) និងធ្វើប្រតិភូកម្មជូនស្រុក ដើម្បីអនុវត្តជាអាណាប័កផ្ទេរសិទ្ធិ ។

**23.** គំរោងចំណូល ចំណាយថវិកាខេត្ត ក្រុងត្រូវបានកែសំរួលបំពេញបន្ថែមតាមទំរង់ដូចមានភ្ជាប់មកជាមួយ នឹងសារាចរណែនាំនេះ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលខេត្ត ក្រុងទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។៚

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង
  (ដើម្បីមុខការ)
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង..............

ឧបសម្ព័ន្ធទី១

# ការគ្រប់គ្រងឆ្នាំ ២០០៦

## តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

| ជំពូក | មាត្រា | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៥ | | | គំរោងឆ្នាំ ២០០៦ |
|---|---|---|---|---|---|---|---|---|
| | | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | | |

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
អ្នកធ្វើតារាង

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# ការគ្រប់គ្រងឆ្នាំ ២០០៦

## តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៥ ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | គំរោងឆ្នាំ ២០០៦ |
|---|---|---|---|---|---|---|---|---|
| | | | | ប្រភេទទី១: ពន្ធ និង អាករ | | | | |
| 10 | | | | **ជំពូក១០: ពន្ធ និង អាករ** | | | | |
| | 08 | | | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | | | | |
| 11 | | | | **ជំពូក១១: ពន្ធលើបេតិកភណ្ឌ** | | | | |
| | 01 | | | ពន្ធប្រថាប់ត្រា | | | | |
| 12 | | | | **ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវាកម្ម** | | | | |
| | 03 | | | ពន្ធប៉ាតង់ | | | | |
| | 04 | 02 | | អាករពិសេស: របបនៃការនាំចូល | | | | |
| | 05 | | | ពន្ធសត្តឃាត | | | | |
| | 08 | | | អាករលើតំលៃបន្ថែម: របបនាំចូល | | | | |
| | | 01 | | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | 02 | | សហគ្រាសដទៃទៀត | | | | |
| | 06 | | | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ | | | | |
| | 07 | | | អាករសំរាប់បំភ្លឺសាធារណៈ | | | | |
| | 09 | | | អាករលើការស្នាក់នៅ | | | | |
| 13 | | | | **ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | | | | |
| | 01 | | | ពន្ធ និង អាករគយពីការនាំចូល | | | | |
| | | 01 | | ពន្ធគយពីការនាំចូល | | | | |
| | | 03 | | តំលៃយកមុនលើការងារគយក្នុងការនាំចូល | | | | |
| | | 04 | | ពន្ធគយលើផលិតផលប្រេងកាត | | | | |
| | | 05 | | អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវ | | | | |
| | 03 | | | ការផាកពិន័យរបស់គយ | | | | |

**បញ្ជាក់:** ចំពោះខេត្ត ក្រុងទាំងឡាយណាដែលមានដូចមុខចំណូលខាងលើ ត្រូវគ្រោងបញ្ចូលទៅក្នុងតារាង ឧបសម្ព័ន្ធទី ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង.............

ឧបសម្ព័ន្ធទី២

# ការគ្រប់គ្រងឆ្នាំ ២០០៦

## តារាងសរុបចំណាយថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

| ជំពូក | ប្រការ | គណនី | អនុគណនី | ការរាយមុខចំណាយ (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៥ | | | គំរោងឆ្នាំ ២០០៦ |
|---|---|---|---|---|---|---|---|---|
| | | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | | |

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
អ្នកធ្វើតារាង

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សញ្ញាកបំផ្ទុះ

ខេត្ត ក្រុង:..........

## ការគ្រប់គ្រងឆ្នាំ ២០០៦

## តារាងសរុបនៃបុគ្គលិក, បៀវត្ស និង ប្រាក់បំណាច់

| បុគ្គលិក / អង្គភាព | បៀវត្ស សរុប | ចំនួនបុគ្គលិក សរុប | ប្រភេទបុគ្គលិកដែលមានសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ | | | | | បុគ្គលិក អណ្តែត | បុគ្គលិក ជាប់កិច្ចសន្យា |
|---|---|---|---|---|---|---|---|---|---|
| | | | បុគ្គ.អចិន្ត្រៃយ៍សរុប | ប្រភេទ"ក" | ប្រភេទ"ខ" | ប្រភេទ"គ" | ប្រភេទ"ឃ" | | |
| សរុប | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សលាកបត្រ២**

ខេត្ត ក្រុង:............

# ការគ្រប់គ្រងឆ្នាំ ២០០៦

## អសង្ហារឹម: ជំពូក១១ - ប្រការ០១ - កថាខ័ណ្ឌ០១

| អសង្ហារឹម / អង្គភាព | សរុប | អសង្ហារឹមប្រើប្រាស់ក្នុងរដ្ឋបាល | | | | អសង្ហារឹមប្រើប្រាស់ក្នុងវាសនដ្ឋាន | | | |
|---|---|---|---|---|---|---|---|---|---|
| | | ០១.ថ្លៃឈ្នួល | ០២.ការរៀបចំ | ០៣.ទឹក | ០៤.អគ្គិសនី | ០១.ថ្លៃឈ្នួល | ០២.ការរៀបចំ | ០៣.ទឹក | ០៤.អគ្គិសនី |
| សរុប | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| ............ | | | | | | | | | |
| ............ | | | | | | | | | |
| ............ | | | | | | | | | |
| ............ | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
សលាកបត្រ៣

ខេត្ត ក្រុង:..........

# ការគ្រប់គ្រងឆ្នាំ ២០០៦
## ចលនវត្ថុ ‐ សម្ភារ: និងសម្ភារ:ការិយាល័យ
## ជំពូក១១ ‐ ប្រការ០១ ‐ កថាខ័ណ្ឌ០២ និង ០៤

| អង្គភាព | សរុប | ចលនវត្ថុ និង សម្ភារ: | | ក្រដាសបោះពុម្ពនិងសម្ភារ:ការិយាល័យ | |
|---|---|---|---|---|---|
| | | ការទិញ | ការថែទាំ | ក្រដាសបោះពុម្ព | សម្ភារ:ការិយាល័យ |
| សរុប | | | | | |
| ខុទ្ទកាល័យ | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| .............. | | | | | |
| .............. | | | | | |
| .............. | | | | | |
| .............. | | | | | |
| .............. | | | | | |
| .............. | | | | | |
| .............. | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សហាកប័ត្រ៤**

ខេត្ត ក្រុង:............

# ការគ្រប់គ្រងឆ្នាំ ២០០៦

## រថយន្ត: ជំពូក១១ - ប្រការ០១ - កថាខ័ណ្ឌ០៧ ទាក្យខ័ណ្ឌ០១ និង ០២

| អង្គភាព | សរុប | ម៉ាករថយន្ត | ផ្លាកលេខ | ឆ្នាំទិញ | ចំនួនគ.មដែលត្រូវរត់ | ការថែទាំ | ប្រេងឥន្ធនៈនិងប្រេងរំអិល |
|---|---|---|---|---|---|---|---|
| សរុប | | | | | | | |
| ខុទ្ទកាល័យ | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| ............ | | | | | | | |
| ............ | | | | | | | |
| ............ | | | | | | | |
| ............ | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សលាកបត្រ៥**

ខេត្ត ក្រុង:................

## ការគ្រប់គ្រងឆ្នាំ ២០០៦

## ចំណាយទូទាត់សោហ៊ុយៈ ជំពូក១១ - ប្រការ០២

| ប្រភេទបេសកកម្ម / អង្គភាព | សរុប | បេសកកម្មនៅក្នុងមណ្ឌល | បេសកកម្មអន្តរមណ្ឌល | | | | បេសកកម្មក្រៅប្រទេស | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ឧបត្ថម្ភរបបបេសកកម្ម | សោ.ដឹកជញ្ជូន | សោ.ហូបចុក | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ដឹកជញ្ជូន | សោ.ហូបចុក | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ផ្សេងៗ |
| សរុប | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| ............ | | | | | | | | | | | |
| ............ | | | | | | | | | | | |
| ............ | | | | | | | | | | | |
| ............ | | | | | | | | | | | |
| ............ | | | | | | | | | | | |
| ............ | | | | | | | | | | | |
| ............ | | | | | | | | | | | |